# ស្មាត បីស៊ីណេស ប្រូក្រាម

ស្មាត បីស៊ីណេស ប្រូក្រាម បានត្រូវរៀបចំឡើង សំរាប់ផ្តល់ការលើកទឹកចិត្ត ខាងហិរញ្ញវត្ថុ ដល់លោកអ្នក ដែលមានមុខរបរតូចតាចក្នុងការដាក់ភ្លើងមិនជាទីគាប់ចិត្ត ដែលមានមកហើយ ឲ្យមានពន្លឺជាទីគាប់ចិត្តឡើងវិញ ។ ប្រាក់ដែលត្រូវបង្វិលឲ្យវិញ មានចំនួនពី $25 ទៅ $65 ក្នុងមួយប្រដាប់ សំរាប់ការតនៅកន្លែងមួយ នៅពេលដាក់ចង្កៀង ឬប្រដាប់ថ្មីជំនួសរបស់ ដែលមានពីមុនមក ។

**អត្ថប្រយោជន៍**
ពន្លឺភ្លើងខាងក្នុង អាចទទួលផលបានដល់ 60% នៃតម្លៃកម្លាំងភ្លើង សំរាប់មុខរបររបស់លោកអ្នក ។
ការតភ្លើងប្រកបដោយប្រសិទ្ធិភាព ផ្តល់លទ្ធផលដូចនេះ:

- បន្ថយតម្លៃថាមពល និងតម្លៃការថែទាំ
- បង្កើនគុណភាពពន្លឺ
- បង្កើនផលិតកម្ម ហើយនិងធ្វើបរិយាកាសកន្លែងធ្វើការ ឲ្យមានសន្តិសុខ

**លក្ខណសម្បត្តិ**
មុខរបរតូចតាច នៅក្នុងតំបន់ក្រុមហ៊ុនអគ្គិសនីក្រុងស៊ីអាថុល ដែលស្ថិតនៅលើ Rate Schedule ESMC ឬ ESMS(ធ្លាប់មាន កំរិត 31 និង 56)ហើយមិនមែនជាផ្នែកនៃផ្លូវ,បរិវេណ ឬមន្ទីរណាមួយ មានលក្ខណសម្បត្តិ ដល់កម្មវិធីនេះទាំងអស់ ។ តារាងកំរិតតម្លៃសំរាប់មុខរបររបស់លោកអ្នក មានចុះនៅលើសំបុត្រទារលុយរបស់លោកអ្នក បើពុំនោះសោត លោកអ្នកអាចទូរស័ព្ទ Conservation Help Line at **206-684-3800** ឬផ្ញើ email ទៅតាមអាសយដ្ឋានខាងក្រោម ដើម្បីបានពត៌មាននេះ ។

**របៀបចូលរួម**
គឺងាយនិងចូលរួមជាទីបំផុត! Seattle City Light នឹងផ្តល់ជូនលោកអ្នក នូវបញ្ជីឈ្មោះជនកុងត្រាភ្លើង ដែលចូលរួម ហើយនិងឈ្មោះអ្នកលក់ ដើម្បីធ្វើការប៉ាន់ប្រមាណ នូវកិច្ចការទាំងនោះ ។ បើមិនដូច្នោះទេ លោកអ្នកអាចជ្រើសយកអ្នកកុងត្រា ដែលមានប័ណ្ណអនុញ្ញាត ដោយខ្លួនឯងក៏បាន ដើម្បីតដាក់រង្វាស់ភ្លើងដែលអនុញ្ញាត ។ សូមទូរស័ព្ទ **206-684-3800** ឬផ្ញើ email ទៅតាមអាសយដ្ឋានខាងក្រោម ដើម្បីបញ្ជាក់មើល ក្រែងមុខរបររបស់លោកអ្នក មានលក្ខណសម្បត្តិ ហើយនិងដើម្បីបានទទួល កូនកញ្ចប់ពត៌មាន ។ Seattle City Light មិនមានចេញលិខិតយល់ព្រម ឬធ្វើការបញ្ជូនបន្ត ថាឲ្យលោកអ្នកទៅរកជនកុងត្រា ឬជនអ្នកលក់ណាមួយឡើយ ។ កម្មវិធីលើកទឹកចិត្ត អាចផ្លាស់ប្តូរបាន យោលទៅលើលទ្ធភាពនៃប្រាក់ជំនួយ ។

**Central Area Neighborhood Power Project(ទំរង់ថាមពលណេបរ័ហ៊ូដ តំបន់កណ្តាល)**
សូមប្រាប់យើងឲ្យដឹង បើមុខរបរលោកអ្នក នៅតំបន់កណ្តាល ពេលលោកអ្នកទូរស័ព្ទមកយើង អំពីកម្មវិធនេះ ។ លោកអ្នកអាចមានលក្ខណសម្បត្តិ ដល់ការលើកទឹកចិត្តពិសេសទៀត ។

**ពត៌មានច្រើនទៀត:** ដើម្បីបានទទួលពត៌មាន ស្មាត បីស៊ីណេស ប្រូក្រាម សព្វគ្រប់,សូមទូរស័ព្ទ Charles Valentin តាមលេខ: **206-684-4215**, ឬផ្ញើ email ទៅតាមអាសយដ្ឋានខាងក្រោម ។